ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ធំ

លេខ៖ ✓ សជណ

ថ្ងៃច័ន្ទ ១៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
កំពង់ធំ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំព្រឹត្តិការណ៍បាល់ទាត់ដណ្តើមពានរង្វាន់ “យុវជនខេត្តកំពង់ធំ ឆ្នាំ២០១៩”

តាមការដឹកនាំ និងចង្អុលបង្ហាញពីឯកឧត្តមអភិបាលខេត្ត រដ្ឋបាលខេត្តមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាប្រធានស្ថាប័ន អង្គភាពរដ្ឋ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាប័នឯកជន រដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្តកំពង់ធំមេត្តាជ្រាបថា ដើម្បីចូលរួមចំណែកលើកកម្ពស់វិស័យបាល់ទាត់នៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសខេត្តកំពង់ធំឱ្យកាន់តែមានសកម្មភាពរស់រវើក និងរីកចម្រើនកាន់តែប្រសើរខ្លាំងក្លាបន្ថែមទៀត សំដៅបណ្តុះស្មារតីស្រឡាញ់កីឡា សុខភាព ចៀសឆ្ងាយពីគ្រឿងញៀន ព្រមទាំងរឹតចំណងមិត្តភាព សាមគ្គីភាព និងបង្កើនភាពស្និតស្នាលរវាងយុវជន និងយុវជន រដ្ឋបាលខេត្តបានសម្រេចបង្កើតឱ្យមានព្រឹត្តិការណ៍បាល់ទាត់ដណ្តើមពានរង្វាន់ **“យុវជនខេត្តកំពង់ធំឆ្នាំ២០១៩”**។

ក្រុមដែលត្រូវចូលរួមក្នុងពានរង្វាន់នេះ ត្រូវបំពេញទម្រង់បែបបទតាមគោលការណ៍ណែនាំលក្ខខណ្ឌ និងចូលរួមប្រកួត តាមកាលបរិច្ឆេទ និងទីកន្លែងដូចខាងក្រោម៖

១- **លក្ខខណ្ឌសម្រាប់ក្រុមចូលរួមប្រកួត៖**

ក-ក្រុមចូលរួមប្រកួតកំណត់ត្រឹម ១៦ក្រុម ដែលបានដាក់ពាក្យសុំចូលរួមប្រកួតនឹងត្រូវបានធ្វើការជ្រើសរើសដោយគណៈ កម្មការរៀបចំការប្រកួត

ខ-ក្រុមដែលមកដាក់ពាក្យចូលរួមការប្រកួតត្រូវតម្កល់ប្រាក់ចំនួន ១.០០០.០០០រៀល (មួយលានរៀល)

គ-ប្រាក់តម្កល់ចំនួន ១.០០០.០០០រៀល (មួយលានរៀល) ក្រោយពីការទូទាត់ពិន័យកាតលឿង កាតក្រហម និងការប្តឹងតវ៉ាផ្សេងៗ នឹងត្រូវប្រគល់ជូនក្រុមវិញ ក្រោយពានរង្វាន់នេះបញ្ចប់ជាស្ថាពរ។

២- កាលបរិច្ឆេទប្រកួត៖ ពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩ រៀងរាល់ថ្ងៃសុក្រ ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ

-ថ្ងៃសុក្រ វេលាម៉ោង ៣: ០០នាទីរសៀល

-ថ្ងៃសៅរ៍ វេលាម៉ោង ៨: ០០នាទីព្រឹក និងវេលាម៉ោង ៣: ០០នាទីរសៀល

-ថ្ងៃអាទិត្យ វេលាម៉ោង ៨: ០០នាទីព្រឹក និងវេលាម៉ោង ៣: ០០នាទីរសៀល

(ដោយយោងលើការដាក់ពាក្យលើសចំនួនកំណត់ និងរៀបចំការប្រកួតជំរុះ)

៣- កាលបរិច្ឆេទ នៃការទទួលពាក្យ៖ គណៈកម្មការរៀបចំការប្រកួតចាប់ទទួលពាក្យពីថ្ងៃជូនដំណឹងតទៅ។

៤- ទីកន្លែងទទួលពាក្យសុំចូលរួមប្រកួត៖ ការិយាល័យអប់រំកាយ និងកីឡា នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ។

៥- កាលបរិច្ឆេទប្រជុំ៖ កម្មវិធីប្រជុំស្តីពីដំណើរការប្រកួតគណៈកម្មការរៀបចំនឹងជូនដំណឹងបន្ទាប់ពីបានបិទបញ្ចប់ការទទួលពាក្យចូលរួមប្រកួត

-កាលបរិច្ឆេទបិទបញ្ចប់ទទួលពាក្យចូលរួមប្រកួត ៖ **ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៩**

-កាលបរិច្ឆេទបិទការប្រកួត ៖ **ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៩** (គណៈកម្មការរៀបចំព្រឹត្តិការណ៍កីឡាបាល់ទាត់ដណ្តើមពានរង្វាន់ "យុវជនខេត្តកំពង់ធំឆ្នាំ២០១៩" សូមរក្សាសិទ្ធកែប្រែកាលបរិច្ឆេទបិទការប្រកួត)។

៦- ទីកន្លែងប្រកួត៖ កីឡដ្ឋានខេត្ត និងទីលានបាល់ទាត់កងរាជអាវុធហត្ថខេត្ត។

៧- ប្រព័ន្ធប្រកួត៖ ការប្រកួតអនុវត្តតាមប្រព័ន្ធវិលជុំ និងជំរុះ។

៨- ឯកសារសម្រាប់ចុះបញ្ជីមន្ត្រីក្រុម៖

ក- ទម្រង់ការចុះបញ្ជីមន្ត្រីផ្លូវការ

ខ- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

(ត្រូវបង្ហាញច្បាប់ដើមដើម្បីផ្ទៀងផ្ទាត់ពេលណាដែលត្រូវបានស្នើសុំដោយគណៈកម្មការប្រកួត)

គ-រូបថតពណ៌ធម្មជាតិទំហំ ៤x៦ ចំនួន ០១សន្លឹក (រូបថតថ្មី)

ឃ-គណៈកម្មការប្រកួតអាចស្នើសុំឱ្យក្រុមផ្តល់ឯកសារលើសពីនេះ ក្នុងករណីចាំបាច់។

៩- គោលការណ៍ នៃការចុះបញ្ជីកីឡាករ៖

ក- ក្រុមអាចចុះបញ្ជីកីឡាករដំបូងយ៉ាងតិចចំនួន ១៨នាក់ និងយ៉ាងច្រើនចំនួន ២៥នាក់

ខ- បើក្រុមណាមួយខកខានក្នុងការចុះបញ្ជីកីឡាករដំបូងចំនួនតិចជាង ១៨នាក់ គណៈកម្មការរៀបចំការប្រកួតចាត់ទុកថាក្រុមបានដកខ្លួនចេញពីការប្រកួត

គ- ក្រុមទាំងអស់ត្រូវចុះបញ្ជីកីឡាករអ្នកចាំទីមានចំនួនយ៉ាងតិច ០១នាក់

ឃ-គ្រប់ព័ត៌មាននៅក្នុងទម្រង់ចុះបញ្ជី ត្រូវតែបំពេញឱ្យបានពេញលេញ

ង-កីឡាករដែលមិនមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវ និងមិនត្រូវបានចុះបញ្ជីទេ

ច-ក្រុមចូលរួមមានការទទួលខុសត្រូវដោយខ្លួនឯងក្នុងការបញ្ជូនទម្រង់ចុះបញ្ជីកីឡាករ និងឯកសារពាក់ព័ន្ធមកគណៈកម្មការរៀបចំការប្រកួតឱ្យទាន់ពេលវេលា

ឆ-មន្ត្រី ឬកីឡាករម្នាក់មានសិទ្ធចុះឈ្មោះតែមួយក្រុម។

១០- ការចុះបញ្ជីកីឡាករដំណាក់កាលដំបូង៖

ក-ក្រុមដែលមានបំណងចូលរួមការប្រកួតនេះ ត្រូវបញ្ជូនឯកសារទម្រង់ចុះបញ្ជីកីឡាករផ្លូវការមកកាន់គណៈកម្មការរៀបចំការប្រកួតរួមជាមួយឯកសារចាំបាច់ផ្សេងទៀតឱ្យបានទាល់ពេលវេលាដែលកំណត់ដោយគណៈកម្មការប្រកួត

ខ-ក្រោយពេលដែលគណៈកម្មការប្រកួត បានទទួលទម្រង់ចុះបញ្ជីកីឡាករផ្លូវការពីក្រុមនីមួយៗមួយពេលវេលាកំណត់ឈប់ទទួលពាក្យត្រូវបានផុត ក្រុមអាចស្នើសុំផ្លាស់ប្តូរបាន មុន៧ថ្ងៃមុនដំណើរការប្រកួត

គ-ការចុះបញ្ជីកីឡាដំបូងមានចំនួនមិនតិចជាង ១៨នាក់ និងមិនលើសពី ២៥នាក់

ឃ-កីឡាករដែលលេងនៅក្នុងលីគអាជីព(លីគ១ លីគ២) របស់សហព័ន្ធបាល់ទាត់កម្ពុជា និងពានរង្វាន់សម្តេចហ៊ុនសែន មិនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះចូលរួមការប្រកួតនេះឡើយ។

១១- ការចុះបញ្ជីកីឡាករដំណាក់កាលចុងក្រោយ៖

ក្រុមនីមួយៗត្រូវបញ្ជូនទម្រង់ចុះបញ្ជីកីឡាករផ្លូវការចុងក្រោយមានចំនួនមិនតិចជាង ១៨នាក់ និងមិនលើសពី ២២នាក់ ដែលជ្រើសចេញពីបញ្ជីកីឡាករផ្លូវការដំបូង (២៥នាក់) ២៤ម៉ោងមុនការប្រកួតនីមួយៗរបស់ខ្លួន។

១២- បញ្ជីកីឡាករចាប់ផ្តើមការប្រកួត៖

ក្រុមនីមួយៗត្រូវផ្តល់បញ្ជីកីឡាករចាប់ផ្តើមប្រកួត និងបញ្ជីមន្ត្រីអង្គុយនៅកៅអីក្រុម មកអនុគណៈកម្មការបច្ចេកទេស រៀបចំការប្រកួត នឹងទីលាន យ៉ាងយឺតបំផុត ៩០នាទីមុនការប្រកួតចាប់ផ្តើម។ បញ្ជីកីឡាករចាប់ផ្តើមត្រូវមានបញ្ជាក់កីឡាករ ១១នាក់ ដំបូង កីឡាករបម្រុង កីឡាករមិនលេង និងប្រធានក្រុម។ បើមានការយឺតយ៉ាវក្នុងការផ្តល់បញ្ជីចាប់ផ្តើមការប្រកួតក្រុម នឹងទទួលខុសត្រូវចំពោះវិធានការវិន័យពីគណៈកម្មការប្រកួត។

១៣- គោលការណ៍នៃការចុះបញ្ជីមន្ត្រីក្រុម៖

ក- ក្រុមអាចចុះបញ្ជីមន្ត្រីយ៉ាងតិចចំនួន ០៣នាក់ ក្នុងទម្រង់របស់គណៈកម្មការប្រកួត

ខ- គ្រប់ព័ត៌មាននៅក្នុងទម្រង់ចុះបញ្ជី ត្រូវតែបំពេញឱ្យបានពេញលេញ

គ- មន្ត្រីដែលមិនមានឯកសារគ្រប់គ្រាន់ ត្រឹមត្រូវ និងមិនត្រូវបានចុះបញ្ជីទេ។ មន្ត្រីដែលបានចុះបញ្ជីនឹងត្រូវបានផ្តល់បណ្ណសម្គាល់មន្ត្រី។

១៤- ការចុះឈ្មោះក្រុម៖

ក្រុមនីមួយៗ ត្រូវដាក់ពាក្យចូលរួមការប្រកួត ដែលមានឯកសារដូចខាងក្រោម៖

ក- ចុះឈ្មោះក្រុមរដ្ឋបាលក្រុង ស្រុក ឬអង្គភាព ស្ថាប័នរដ្ឋ ធនាគារ គ្រឹះស្ថានឯកជន( ទម្រង់១ )

ខ- ពាក្យសុំចូលរួមប្រកួត ( ទម្រង់២ )

គ- សេចក្តីប្រកាស ( ទម្រង់៣ )

ឃ- បញ្ជីមន្ត្រី (ឈ្មោះអ្នកដឹកនាំ គ្រូបង្វឹក និងជំនួយការ )មានបិទរូបថត ( ទម្រង់៤ )

ង- បញ្ជីកីឡាករ( Album )មានបិទរូបថត ( ទម្រង់៥ )

ច- ពណ៌ឯកសណ្ឋានក្រុម ( ទម្រង់៦ )

ឆ- រូបថតពណ៌ធម្មជាតិ (ថ្មី) ទំហំ ៤x៦ ចំនួន ០១សន្លឹក (រូបថតបច្ចុប្បន្ន)

១៥- លក្ខណៈសម្បត្តិកីឡាករ៖

ក- មានអាយុចាប់ពី ១៦ឆ្នាំ ឡើងទៅ

ខ- មានសញ្ជាតិខ្មែរ និងមានទីកន្លែងកំណើត អាសយដ្ឋានបច្ចុប្បន្នក្នុងខេត្តកំពង់ធំ

គ- បញ្ហាសុខភាពកីឡាករ ត្រូវទទួលខុសត្រូវដោយខ្លួនឯង

ឃ- កីឡាករនឹងត្រូវចាត់ទុកថាមិនមានភាពស្របច្បាប់ប្រសិនបើ៖

- បើគណៈកម្មការប្រកួតរកឃើញថា ឯកសារពាក់ព័ន្ធរបស់កីឡាករមិនមានភាពត្រឹមត្រូវ ឬក្លែងបន្លំ
- កីឡាករដែលមានឈ្មោះលេងក្នុងលីគអាជីព(លីគ១ លីគ២) និងពានរង្វាន់សម្តេចហ៊ុនសែនរបស់កម្ពុជា
- ក្នុងករណីរកឃើញមានកំហុស ក្រុមនិមួយៗនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

១៦- ពានរង្វាន់៖

| | | |
|---|---|---|
| ១- ជ័យលាភីចំណាត់ថ្នាក់លេខ១ | ៖ | ទទួលបានថវិកាចំនួន ៨.០០០.០០០ រៀល (ប្រាំបីលានរៀល) អមជាមួយពានរង្វាន់០១ និងមេដាយមាសចំនួន ៣៣គ្រឿង |
| ២- ជ័យលាភីចំណាត់ថ្នាក់លេខ២ | ៖ | ទទួលបានថវិកាចំនួន ៦.០០០.០០០ រៀល (ប្រាំមួយលានរៀល) និងមេដាយចំនួន ៣៣គ្រឿង |
| ៣- ជ័យលាភីចំណាត់ថ្នាក់លេខ៣ | ៖ | ទទួលបានថវិកាចំនួន ៣.០០០.០០០ រៀល (បីលានរៀល) និងមេដាយចំនួន ៣៣គ្រឿង |

៤- ក្រុមលេងល្អជាងគេ ៖ ទទួលបានថវិការចំនួន ៥០០.០០០ រៀល (ហាសិបម៉ឺនរៀល)

៥- កីឡាករសុតបញ្ចូលទីច្រើនជាងគេ ៖ ទទួលបានថវិការចំនួន ៥០០.០០០ រៀល (ហាសិបម៉ឺនរៀល)

៦- កីឡាករលេងល្អជាងគេ ៖ ទទួលបានថវិការចំនួន ៥០០.០០០ រៀល (ហាសិបម៉ឺនរៀល)

៧- កីឡាករអ្នកចាំទីល្អជាងគេ ៖ ទទួលបានថវិការចំនួន ៥០០.០០០ រៀល (ហាសិបម៉ឺនរៀល)

៨- គ្រូបង្វឹកល្អជាងគេ ៖ ទទួលបានថវិការចំនួន ៥០០.០០០ រៀល (ហាសិបម៉ឺនរៀល)

១៧- ទំនាក់ទំនង៖

ដើម្បីងាយស្រួលដល់ការធ្វើទំនាក់ទំនង ក្រុមទាំងអស់ត្រូវមានអាសយដ្ឋានអ៊ីម៉ែល ឬ Telegram ហើយផ្ញើមកគណៈកម្មការប្រកួតនៅពេលដាក់ពាក្យ តាមរយៈអាសយដ្ឋាន៖ ការិយាល័យអប់រំកាយ និងកីឡា នៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ ដែលមានទីតាំងស្ថិតនៅ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

<u>ទូរស័ព្ទលេខ ឬ Telegram</u> ៖

| | | |
|---|---|---|
| ១-លោក សាន វុទ្ធី | 092 78 31 44 | Telegram 092 78 31 44 |
| ២-លោក ឃឹម សេង | 011 90 45 11 | Telegram 011 90 45 11 |
| ៣-លោក លឹម សុភាព | 089 49 47 67 | Telegram 089 49 47 67 |
| ៤-លោក អ៊ុក ចន្ថា | 077 63 61 76 | |
| ៥-លោក ជា សម្បត្តិ | 012 72 75 59 | Telegram 012 72 75 59 |

ចំណាំ៖ ដើម្បីងាយស្រួលដល់ការចុះបញ្ជី សូមមេត្តាបំពេញឱ្យបានគ្រប់ចន្លោះ និងដោយកុំព្យូទ័រ។

គណៈកម្មការរៀបចំព្រឹត្តិការណ៍បាល់ទាត់ដណ្តើមពានរង្វាន់ " **យុវជនខេត្តកំពង់ធំ ឆ្នាំ២០១៩** " សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាប្រធានស្ថាប័ន អង្គភាពរដ្ឋ ធនាគារ គ្រឹះស្ថានឯកជន រដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្តកំពង់ធំ សូមមេត្តារួសរាន់ ដាក់ពាក្យចូលរួមការប្រកួតឱ្យបានទាន់ពេលវេលា និងត្រៀមលក្ខណៈសម្បត្តិរៀបចំក្រុមចូលរួមការប្រកួតបានល្អប្រសើរ។

សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ទទួលនូវការគោរពរាប់អានពីយើងខ្ញុំ។

**រដ្ឋបាលខេត្តកំពង់ធំ**